# សេចក្ដីពន្យល់ដោយសង្ខេប
# ស្ដីពី
# សិទ្ធិលើការបញ្ចាំ និងការបញ្ចាំអចលនវត្ថុ

## សេចក្ដីផ្ដើម

នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ប្រជាពលរដ្ឋតែងតែត្រូវការដើមទុន ដើម្បីប្រកបអាជីវកម្ម ឬធ្វើសកម្មភាពជំនួញផ្សេងៗ ហើយបានយកទ្រព្យសម្បត្តិរបស់ខ្លួនទៅដាក់បញ្ចាំជាមួយម្ចាស់បំណុល ដើម្បីធានាបំណុល ប៉ុន្តែប្រជាពលរដ្ឋខ្លះក៏មិនទាន់បានយល់ច្បាស់ពី អ្វីដែលហៅថា ការបញ្ចាំ ។

តើគេអាចដាក់បញ្ចាំអ្វីខ្លះ? តើម្ចាស់បំណុលដែលមានសិទ្ធិលើការបញ្ចាំមានសិទ្ធិអ្វីខ្លះ ? តើអានុភាព និងលក្ខខណ្ឌនៃការបញ្ចាំមានលក្ខណៈដូចម្ដេច?

ខាងក្រោមនេះ គ្រាន់តែជាអត្ថបទពន្យល់ដោយសង្ខេបពីការបញ្ចាំសម្រាប់ប្រជាពលរដ្ឋទូទៅស្វែងយល់ពីទិដ្ឋភាពច្បាប់ពីសិទ្ធិលើការបញ្ចាំនេះ។

## ១. តើអ្វីជាសិទ្ធិលើការបញ្ចាំ ?

សិទ្ធិលើការបញ្ចាំ ជាសិទ្ធិកាន់កាប់វត្ថុដែលបានទទួលពីកូនបំណុល ឬតតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួន ពីវត្ថុនោះដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។

កម្មវត្ថុនៃសិទ្ធិលើការបញ្ចាំអាចជាចលនវត្ថុ អចលនវត្ថុ និងសិទ្ធិលើទ្រព្យសម្បត្តិ (យោងតាមមាត្រា ៨១៦ និងមាត្រា ៨៤០ នៃក្រមរដ្ឋប្បវេណី)។

## ២. ការបង្កើតសិទ្ធិលើការបញ្ចាំ

ការបញ្ចាំកើតឡើងដោយការព្រមព្រៀងរបស់គូភាគី ដែលក្នុងនោះ កូនបំណុល ឬតតិយជនដែលបានបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ។

ហេតុនេះ ការព្រមព្រៀងបង្កើតសិទ្ធិលើការបញ្ចាំដោយកូនបំណុល និងប្រគល់វត្ថុបញ្ចាំទៅឲ្យម្ចាស់បំណុលជាលក្ខខណ្ឌដាច់ខាត។ នេះមានន័យថាម្ចាស់បំណុលជាអ្នកកាន់កាប់វត្ថុបញ្ចាំ រីឯកូនបំណុលមិនអាចកាន់កាប់វត្ថុបញ្ចាំទេ។ ក្នុងករណីនេះ ម្ចាស់បំណុលមានសិទ្ធិឃាត់ទុកវត្ថុបញ្ចាំ បើកូនបំណុលមិនអនុវត្តកាតព្វកិច្ចសងបំណុលមកវិញ នៅពេលដល់កំណត់សង។ ប៉ុន្តែសិទ្ធិនេះមិនអាចតតាំងចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ (យោងតាមមាត្រា ៨២១ នៃក្រមរដ្ឋប្បវេណី)

## ៣.សិទ្ធិរបស់ម្ចាស់បំណុល

តើម្ចាស់សិទ្ធិលើការបញ្ចាំ (ម្ចាស់បំណុល)មានសិទ្ធិអ្វីខ្លះ?

យោងតាមបញ្ញត្តិក្រមរដ្ឋប្បវេណី ម្ចាស់បំណុលមានសិទ្ធិដូចតទៅ ៖

- ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវកាន់កាប់វត្ថុបញ្ចាំ
- ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិឃាត់ទុកវត្ថុបញ្ចាំ
- ម្ចាស់សិទ្ធិលើការបញ្ចាំអាចទទួលផលដែលកើតពីវត្ថុបញ្ចាំ និងអាចយកផលនោះ មកកាត់សិទ្ធិលើបំណុលរបស់ខ្លួន។ ផលនោះត្រូវយកមកកាត់ការប្រាក់ នៃសិទ្ធិលើបំណុលជាមុនសិន ហើយបើមានសំណល់ ត្រូវយកទៅកាត់ប្រាក់ដើម។
- ម្ចាស់សិទ្ធិលើការបញ្ចាំ អាចទាមទារឲ្យកម្មសិទ្ធិករនៃវត្ថុ (កូនបំណុល) នោះត្រូវ សងនូវចំណាយនានាដែលម្ចាស់បំណុល ឬ ម្ចាស់សិទ្ធិលើការបញ្ចាំនោះបានចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាវត្ថុបញ្ចាំនោះ។

- ម្ចាស់សិទ្ធិលើការបញ្ចាំអាចយកវត្ថុបញ្ចាំនោះទៅដាក់បញ្ចាំបន្តទៀតបានដោយទទួលការយល់ព្រមពីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល ឬតតិយជន) ដើម្បី ធានានូវកាតព្វកិច្ចរបស់ខ្លួន។ ប៉ុន្តែម្ចាស់សិទ្ធិលើការបញ្ចាំនៅតែអាចយកវត្ថុបញ្ចាំ នោះទៅបញ្ចាំបន្តទៀតបាន ទោះបីគ្មានការយល់ព្រមពីកូនបំណុល ឬអ្នកបង្កើតសិទ្ធិក៏ដោយ។ ក្នុងករណីនេះ ម្ចាស់បំណុល (ម្ចាស់សិទ្ធិលើការបញ្ចាំ) ត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើង។

## ៤. ការហាមកិច្ចសន្យាបញ្ចាំផ្ដាច់

ទោះកិច្ចសន្យាបញ្ចាំត្រូវបង្កើតឡើងតាមការព្រមព្រៀងរវាង ម្ចាស់បំណុល និងកូនបំណុលក៏ដោយ ក៏ច្បាប់មិនឲ្យបង្កើតនូវកិច្ចសន្យាបញ្ចាំផ្ដាច់ដែលបានធ្វើមុនពេលកំណត់ពេលត្រូវសងបានទេ។ ប៉ុន្តែច្បាប់មិនបានហាមឃាត់ម្ចាស់បំណុលទទួលកម្មសិទ្ធិលើវត្ថុបញ្ចាំ ឬចាត់ចែងវត្ថុបញ្ចាំ ដែលធ្វើក្រោយពេលកំណត់សងនៃកិច្ចសន្យាបញ្ចាំទេ។ (យោងតាមមាត្រា ៨២៧ នៃក្រមរដ្ឋប្បវេណី)

## ៥. ការបញ្ចាំចលនវត្ថុ

កិច្ចសន្យាបញ្ចាំចលនវត្ថុ កើតចេញពីការព្រមព្រៀងរវាងអ្នកបង្កើតសិទ្ធិលើការបញ្ចាំ (កូនបំណុល ឬតតិយជន) និងម្ចាស់បំណុល (ម្ចាស់សិទ្ធិលើការបញ្ចាំ) ដោយកូនបំណុល ត្រូវប្រគល់វត្ថុបញ្ចាំទៅឲ្យម្ចាស់បំណុល ធ្វើការកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំ។

ហេតុនេះ កិច្ចសន្យាបញ្ចាំចលនវត្ថុមិនតម្រូវឲ្យមានការចុះបញ្ជីទេ គឺគ្រាន់តែប្រគល់ការកាន់កាប់វត្ថុបញ្ចាំពីកូនបំណុលទៅម្ចាស់បំណុល នោះកិច្ចសន្យាមានអានុភាពហើយ។ ម្ចាស់បំណុលអាចយកសិទ្ធិនៃការកាន់កាប់វត្ថុបញ្ចាំជានិរន្តន៍នេះទៅធ្វើការតតាំងជាមួយតតិយជនផ្សេងទៀតបាន។ ក្នុងករណីតតិយជនដកហូតវត្ថុបញ្ចាំនេះ ម្ចាស់បំណុលនៅតែអាចយកវត្ថុ បញ្ចាំមកវិញបានតាមរយៈបណ្ដឹងទាមទារឲ្យប្រគល់វត្ថុកាន់កាប់មកវិញ។ ដូច្នេះ លក្ខខណ្ឌតតាំងនៃសិទ្ធិលើការបញ្ចាំ គឺការកាន់កាប់វត្ថុបញ្ចាំ។

## ៦. ការប្រើប្រាស់ ឬអាស្រ័យផលពីវត្ថុបញ្ចាំ (ចលនវត្ថុ)

**តើម្ចាស់សិទ្ធិលើការបញ្ចាំ (ម្ចាស់បំណុល) អាចយកវត្ថុបញ្ចាំ មកប្រើប្រាស់បានឬទេ?**

យោងតាមមាត្រា ៨៣១ នៃក្រមរដ្ឋប្បវេណី ម្ចាស់បំណុលមិនអាចយកវត្ថុដែលដាក់បញ្ចាំមកប្រើប្រាស់ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ឬជួលបានទេ បើគ្មានការយល់ព្រមពីកូនបំណុល ឬអ្នកបង្កើតសិទ្ធិលើការបញ្ចាំ។ ប៉ុន្តែម្ចាស់សិទ្ធិលើការបញ្ចាំអាចប្រើប្រាស់វត្ថុបញ្ចាំត្រឹមកម្រិតចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំនោះដោយមិនចាំបាច់ មានការយល់ព្រមពីកូនបំណុល ឬ អ្នកបង្កើតសិទ្ធិលើការបញ្ចាំបាន ប៉ុន្តែមិនអាចជួលវត្ថុបញ្ចាំបានទេ។

ក្នុងករណីម្ចាស់បំណុលប្រើប្រាស់ ឬជួលវត្ថុបញ្ចាំដោយគ្មានការយល់ព្រមពីកូនបំណុល ឬមិនមានភាពចាំបាច់ក្នុងការរក្សាវត្ថុបញ្ចាំទេ នោះកូនបំណុល ឬ អ្នកបង្កើតសិទ្ធិលើការបញ្ចាំ អាចទាមទារកំណត់សិទ្ធិលើការបញ្ចាំបាន។

## ៧. ការអនុវត្តសិទ្ធិលើការបញ្ចាំចលនវត្ថុ

ក្នុងករណីម្ចាស់បំណុល ឬម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ មិនបានទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនទេ នោះម្ចាស់បំណុលអាចទាមទារទៅតុលាការឲ្យយកវត្ថុបញ្ចាំមកសងផ្ទាល់តែម្តង ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីនៃការអនុវត្តដោយបង្ខំ ដើម្បីកាត់សិទ្ធិលើបំណុល។

នេះមានន័យថា ម្ចាស់បំណុលទទួលបាននូវកម្មសិទ្ធិលើវត្ថុបញ្ចាំមិនមែនដោយសារសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ឬដោយកិច្ចសន្យាដែលធ្វើមុនពេលកំណត់ត្រូវបានសងទេ គឺបានតាមរយៈតុលាការ។

**សូមអរគុណ**